**ថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១៣**

# សេចក្តីប្រកាសព័ត៌មានរួម
# រវាងឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអ្នកជំនាញការពិសេសរបស់អគ្គលេខាធិការ អ.ស.ប ទទួលបន្ទុកសាលាក្តីខ្មែរក្រហម

ការស្លាប់របស់ អៀង សារី ដែលជាជនជាប់ចោទមួយរូបក្នុងសំណុំរឿង ០០២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ ២០១៣ បានផ្តោតការចាប់អារម្មណ៍ទៅលើសារសំខាន់ដ៏ចម្បងនៃការពន្លឿនដំណើរការឲ្យបានឆាប់រហ័សតាមតែអាចធ្វើទៅបាន និងប្រកបដោយភាពត្រឹមត្រូវព្រមទាំងមានប្រសិទ្ធភាព សម្រាប់ដំណើរការនីតិវិធីដ៏ត្រឹមត្រូវលើជនជាប់ចោទដែលនៅរស់រានមានជីវិត។ វ័យចាស់ជរារបស់ជនជាប់ចោទ និងកង្វះហិរញ្ញវត្ថុ សម្រាប់ភាគីជាតិ និងអន្តរជាតិនៃ អ.វ.ត.ក នាំឲ្យមានការចាប់អារម្មណ៍ភ្លាមៗពីសំណាក់ភាគីពាក់ព័ន្ធនានា។

នៅថ្ងៃនេះ អ្នកជំនាញការពិសេសរបស់អគ្គលេខាធិការ អ.ស.ប ទទួលបន្ទុកសាលាក្តីខ្មែរក្រហម ឯកឧត្តម **ដាវីដ សេហ្វ័រ** និងឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររបស់រាជរដ្ឋាភិបាលសម្រាប់ដំណើរការសាលាក្តីខ្មែរក្រហមបានជួបប្រជុំគ្នាមួយ ក្រោមបរិយាកាសយោគយល់គ្នាទៅវិញទៅមក បន្ទាប់ពីមានការពិភាក្សាគ្នាជាបឋមនៅប៉ុន្មានថ្ងៃចុងក្រោយនេះ នៅទីក្រុងភ្នំពេញ។ កិច្ចប្រជុំនេះមានគោលបំណងរិះរកដំណោះស្រាយជុំវិញបញ្ហាកង្វះថវិកាធ្វើយ៉ាងណាអាចជួយឲ្យ អ.វ.ត.ក បំពេញបេសកកម្មរបស់ខ្លួនក្នុងការស្វែងរកយុត្តិធម៌លើបទឧក្រិដ្ឋដែលបានកើតមាននៅក្នុងរបបខ្មែរក្រហម។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងអ្នកជំនាញការពិសេស បានទទួលស្គាល់ថា អ.វ.ត.ក បានបំពេញនូវកិច្ចការដ៏សំខាន់ក្នុងការបញ្ចប់សំណុំរឿង ០០១ ដោយជោគជ័យដែលមានជនជាប់ចោទមួយរូប គឺ កាំង ហ្គេកអ៊ាវ ហៅឌុច អតីតប្រធានមន្ទីរគុកទួលស្លែង ដែលត្រូវបានរកឃើញថា មានពិរុទ្ធភាព និងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ សំណុំរឿង ០០២ ដែលមានជនជាប់ចោទ នួន ជា និងខៀវ សំផន ដែលត្រូវបានជំនុំជម្រះលើបទឧក្រិដ្ឋដ៏យង់ឃ្នង់នៅក្នុងរបបខ្មែរក្រហមកំពុងដំណើរការទៅមុខ ដ៏គួរឲ្យកត់សម្គាល់។ អ.វ.ត.ក សន្យាផ្តល់ព័ត៌មានថ្មីបន្ថែមទៀតដល់ប្រជាជនកម្ពុជា និងដល់ពិភពលោក។ នៅក្នុងរយៈពេល ៦ ឆ្នាំនៃដំណើរការប្រតិបត្តិការរបស់ អ.វ.ត.ក បុគ្គលិក និងមន្ត្រីតុលាការកម្ពុជា បានទទួលនូវបទពិសោធន៍ដ៏គួរឲ្យកត់សម្គាល់ក្នុងការបំពេញការងារក្នុងក្របខ័ណ្ឌរដ្ឋបាលតុលាការទំនើបមួយដែលអនុវត្តតាមនីតិវិធីត្រឹមត្រូវនៃស្តង់ដារអន្តរជាតិ ខណៈដែលការអនុវត្តទាំងនេះ ព្រមទាំងនីតិវិធីមួយចំនួនបាន និងកំពុងផ្ទេរទៅកាន់តុលាការថ្នាក់ជាតិ។

នាឱកាសជំនួបពិភាក្សានោះ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** បានសម្តែងការកោតសរសើរចំពោះការប្តេជ្ញារបស់បុគ្គលិកជាតិទាំងអស់ដែលបាន និងកំពុងបន្តបំពេញកាតព្វកិច្ចរបស់ខ្លួន អំឡុងពេលដ៏លំបាកនេះ។

ប្រសិនបើ អ.វ.ត.ក មិនអាចបំពេញបេសកកម្មរបស់ខ្លួនឲ្យបានពេញលេញទេ នោះវានឹងអាចជាដំណើរត្រឡប់ថយក្រោយមួយដ៏អាក្រក់សម្រាប់ការស្វែងរកយុត្តិធម៌ ហើយក៏អាចបំផ្លាញនូវកិច្ចខិតខំប្រឹងប្រែងដ៏គួរឲ្យកត់សម្គាល់នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះនៅក្នុងការផ្តល់នូវយុត្តិធម៌ដែលបានទន្ទឹងរង់ចាំជាយូរណាស់មកហើយដោយប្រជាជនកម្ពុជាចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។

ការកាត់បន្ថយថវិកាសរុបទាំងអស់ចំនួនជាង ៦.៥ លានដុល្លារអាមេរិក ត្រូវបានធ្វើឡើងនៅក្នុងគម្រោងថវិកាឆ្នាំ ២០១៣ សម្រាប់ភាគីជាតិ និងភាគីអន្តរជាតិ។ ឥឡូវនេះ ឧបសគ្គដែលបន្ទាន់បំផុតនោះ គឺត្រូវធានាថវិកាពេញលេញសម្រាប់ភាគីជាតិ និងភាគីអន្តរជាតិ និងធ្វើឲ្យដំណើរការរបស់ អ.វ.ត.ក មានស្ថិរភាព និងដំណើរការឲ្យបានលឿន ជាមួយកាលវិភាគដ៏ប្រាកដប្រជា លើការជំនុំជម្រះក្តីសំណុំរឿង០០២៕